ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ នាមនាមប្រជារាស្ត្រខ្មែរ

លេខ : ១០១ តុលាការកំពូល

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៥ ខែ មេសា

លេខ : ៣២ ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៦

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក វៀល មួន ចៅក្រម

៤- លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍

៥- លោក យស់ សូខឿន ចៅក្រម

ក្រឡាបញ្ជី

លោក គឹម ថាវី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២៦ "គ" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១០១ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

***ពីបទ*** : ប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិ១ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែមិថុនា ឆ្នាំ២០០៣ តាមបញ្ញត្តិមាត្រា២៥៥ច្បាប់ភូមិបាល ។

១-ជនជាប់ចោទឈ្មោះ **គឹម ជូ** ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១៣ភូមិ២ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

២-ជនជាប់ចោទឈ្មោះ **អ៊ុន សំអឿន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ របររកស៊ី គ្រូបង្រៀន ទីលំនៅសព្វថ្ងៃភូមិ៣ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះអ៊ុក រ៉ិត "ស" ម្តាយឈ្មោះម៉ាក់ ស៊ីវ "ស" ប្រពន្ធឈ្មោះមុំ ចាន់ធួន មានកូន០៤នាក់ ។ ទោសពីមុនគ្មាន ។

-មានមេធាវីលោក សែម ចិន្តា

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ មាស សាឯមដានី (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ របររកស៊ីមេផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ៣០ ផ្លូវម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

-មានមេធាវី លោក នាង ហៃ

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះមាស សាឯមដានី ថា : ខ្លួនសុំប្តឹងពីឈ្មោះ គីម ជូ ភេទស្រី អាយុ៤៩ឆ្នាំ ដោយសំអាងហេតុថា ដីឡូតិ៍នេះជាកម្មសិទ្ធិរបស់ខ្លួនតាំងពីយូរមកហើយ ហើយខ្លួនបានទទួលប័ណ្ណកម្មសិទ្ធិកាន់កាប់នេះត្រឹមត្រូវតាមច្បាប់ ។ ម្យ៉ាងវិញទៀតដីឡូតិ៍របស់ខ្លួននេះ គឺមានអ្នកយាមជាប្រចាំ ទើបតែរយៈពេល៣ខែចុងក្រោយនេះប៉ុណ្ណោះ ខ្លួនបានដកអ្នកយាមចេញ ដោយគាត់មានវ័យចាស់ និង មានជម្ងឺទៀតផង ។

-បានឃើញដីកាតម្កល់រឿងទុកឥតចាត់ការ លេខ៤៩១/០៣ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញា អមតុលាការក្រុងព្រះសីហនុ ដែលបានសំរេច : គប្បីតំកល់រឿងនេះទុកមិនចាត់ការតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៨៩ ចុះថ្ងៃទី០៦-១១-២០០៣ របស់ឈ្មោះមាស សាឯមដានី ប្តឹងមិនសុខចិត្តនឹងដីកាដំកល់រឿងទុកមិនចាត់ការលេខ៤៩១/០៣ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣របស់ព្រះរាជអាជ្ញា អមតុលាការក្រុងព្រះសីហនុ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

+សុំបដិសេធដីកាតំកល់រឿងទុកឥតចាត់ការលេខ៤៩១ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់ អយ្យការ អមតុលាការក្រុងព្រះសីហនុចោលជាអសាបង់ ។

+ចោទប្រកាន់លើឈ្មោះអ៊ុន សំអឿន និងបញ្ជូនទៅចៅក្រមស៊ើបអង្កេតអោយស៊ើបសួរ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៦"គ" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-១១-២០០៣ របស់ឈ្មោះម៉ាស សាឯមដានី ទុកជា ត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធដីកាតំកល់រឿងទុកឥតចាត់ការលេខ៤៩១ ចុះថ្ងៃទី១៣-១០-២០០៣ របស់ព្រះរាជអាជ្ញា អមតុលាការក្រុងព្រះសីហនុចោលជាអសារបង់ ។

៣-ចោទប្រកាន់លើឈ្មោះ អ៊ុន សំអឿន ពីបទប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិ១ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែមិថុនា ឆ្នាំ២០០៣ តាមបញ្ញត្តិមាត្រា២៤៥ នៃច្បាប់ភូមិបាល ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៧៣២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទៅតុលាការក្រុងព្រះសីហនុ ចាត់ការតាមច្បាប់ឡើងវិញ ។

៥-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី , កំបាំងមុខគូក្តី ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១០២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះអ៊ុន សំអឿន ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២៦"គ" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះអ៊ុន សំអឿន "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះមាសសាឯម ដានី "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : គ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះអ៊ុន សំអឿន ពីបទប៉ះពាល់កម្មសិទ្ធិឯកជនប្រព្រឹត្តនៅភូមិ១ សង្កាត់៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែមិថុនា ឆ្នាំ២០០៣ មាត្រា២៥៥ ច្បាប់ភូមិបាល ។

-បានស្តាប់ចំលើយអះអាងរបស់ជនជាប់ចោទឈ្មោះអ៊ុន សំអឿន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ខ្ញុំបាទលក់ដីឱ្យឈ្មោះពិន ស៊ីវុទ្ធី តាមកិច្ចសន្យា ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ មានទំហំ៩០ម៉ែត្រគុណ៦០ម៉ែត្រ ស្ថិតនៅភូមិ១ សង្កាត់៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានព្រំប្រទល់ខាងជើងទល់ដីរួមសាលាគរុកោសល្យ ខាងត្បូងទល់ដីឈ្មោះពេទ្យឆោម ខាងកើតទល់ព្រៃក ខាងលិចទល់ផ្លូវថ្នល់ ក្នុងតំលៃចំនួន៩.៥០០ដុល្លាអាមេរិច ដោយមានប្រធានមណ្ឌលទី១ ចំណារបញ្ជាក់ដឹងឮថាមិនទាន់អោយប្រាក់ផង ពេលនោះមានតែបីនាក់ទេដែលដឹងឮ ។

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៩ ឈ្មោះពិន ស៊ីវុទ្ធី បានសងប្រាក់ខ្ញុំតែចំនួន៥.០០០ដុល្លាអាមេរិកមកឱ្យខ្ញុំបាទទេ ។ រីឯប្រាក់នៅសល់នៅថ្ងៃដដែលនេះដែរ គាត់សុំធ្វើកិច្ចសន្យាថា ត្រូវយកប្រាក់ចំនួន៤.៥០០ដុល្លា មកសងខ្ញុំបាទបង្គ្រប់នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៩ នេះ ជាកំហិត ប៉ុន្តែបើកាលណាគាត់មិនបានយកប្រាក់មកសងខ្ញុំបង្គ្រប់នៅថ្ងៃកំណត់ខាងលើនេះទេ គាត់យល់ព្រមឱ្យខ្ញុំកាត់យកដីលក់នេះចំនួនពាក់កណ្តាលវិញ ដោយគ្មានការតវ៉ាអ្វីទេ ហើយក៏មានប្រធានមណ្ឌលទី១ ដឹងឮផង ។

លុះដល់ថ្ងៃកំណត់សងលុយឈ្មោះពិន ស៊ីវុទ្ធី មិនបានយកប្រាក់មកសងទេ កាលដែលភាគីឈ្មោះមាស សាឯមដានី និងឈ្មោះពិន ស៊ីវុទ្ធី លើកឡើងពាក្យថា ពិន ស៊ីវុទ្ធី មកអង្វរខ្ញុំសុំពន្យាពេលសងប្រាក់សិន រហូតរត់ហ្វូងបានទើបសងប្រាក់ ហើយគាត់ថា ខ្ញុំឯកភាពនោះមិនពិតទេ គឺគាត់គ្រាន់តែឆ្លើយយករួចខ្លួន ។

សំណូមពរមេធាវីការពារជនជាប់ចោទឈ្មោះ សំរេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល អោយខ្ញុំបាទបានរួចផុតពីការចោទប្រកាន់ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ មាស សាឯមដានី "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសែម ចិន្តា ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ អ៊ុន សំអឿន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : មិនត្រឹមត្រូវទេអង្គហេតុជារឿងរដ្ឋប្បវេណីសុទ្ធសាធ គឺកូនក្តីខ្ញុំបាទកាន់កាប់ដីតាំងពីឆ្នាំ១៩៩៩ មករហូតដល់សព្វថ្ងៃ គឺមានកិច្ចសន្យាបានចែងច្បាស់លាស់ ហើយការធ្វើប័ណ្ណកម្មសិទ្ធិចូលទៅដីកូនក្តីខ្ញុំបាទមានភាពមិនប្រក្រតីសោះ ការសំរេចរបស់សាលា-ឧទ្ធរណ៍មានការខ្វះចន្លោះ ។

សំណូមពរអោយកូនក្តីខ្ញុំបានរួចផុតពី ការចោទប្រកាន់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកនាង ហៃ មេធាវីការពារអោយជនជាប់ចោទឈ្មោះ មាស សាឯមដានី "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : កូនក្តីខ្ញុំបាទបានទិញមានលិខិតស្នាមត្រឹមត្រូវពីឆ្នាំ១៩៧៩ ដល់២០០៣ តុលាការថ្នាក់ក្រោមមិនបានចូលរួមវាស់វែងទេ ។

សំណូមពរសូមអោយកូនក្តីខ្ញុំបាទបានគ្រប់គ្រងដីដែលមានទំហំ២៨ម គុណ ៦០ម ដែលឈ្មោះ អ៊ុន សំអឿន លួចយកទៅលក់អោយឈ្មោះគីម ជូ ឡើងវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : ជុំវិញអង្គហេតុពាក់ព័ន្ធលើការទិញលក់ដីសុទ្ធសាធ ដូច្នេះគ្មានភស្តុតាងណាគ្រប់គ្រាន់បញ្ជាក់ថាឈ្មោះអ៊ុន សំអឿន ពីបទប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិ១ សង្កាត់៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែមិថុនា ឆ្នាំ២០០៣ តាមមាត្រា២៥៥ ច្បាប់ភូមិបាល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះអ៊ុន សំអឿន សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះ អ៊ុន សំអឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ពុំមានពិរុទ្ធណាមួយដែលអាចចោទប្រកាន់លើឈ្មោះអ៊ុន សំអឿន ពីបទប៉ះពាល់ដល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិ១ សង្កាត់៣ ខ័ណ្ឌមិត្តភាពក្រុងព្រះសីហនុ កាលពីខែមិថុនា ឆ្នាំ២០០៣ តាមបញ្ញត្តិមាត្រា២៥៩ នៃច្បាប់ភូមិបាលនោះទេ ពីព្រោះថា ឈ្មោះពិន ស៊ីវុទ្ធី ដែលជាអ្នកទិញដីទំនាស់ពី អ៊ុន សំអឿន បានទទួលស្គាល់ថា ខ្លួនពិតជាពុំទាន់បានឱ្យប្រាក់បង្គ្រប់ថ្លៃដីដែលទិញពី អ៊ុន សំអឿន ចំនួន ៤.០០០ដុល្លារ(បួនពាន់ដុល្លាអាមេរិក)ទៅ អ៊ុន សំអឿន នៅឡើយ ។ ម្យ៉ាងវិញទៀតក្នុងកិច្ចសន្យាក៏បានសរសេរច្បាស់ថា បើដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៩ បើឈ្មោះពិន ស៊ីវុទ្ធី ពុំទាន់បានប្រគល់ប្រាក់ថ្លៃដីគ្រប់ទេ នោះឈ្មោះអ៊ុន សំអឿន មានសិទ្ធិកាត់យកដី ២៤ម×៦០ម ដែលជាចំណែកនៃប្រាក់នេះវិញ ដែលបញ្ជាក់ថា អ៊ុន សំអឿន ពុំទាន់បាត់សិទ្ធិជាម្ចាស់ដី ហើយលោកពិន ស៊ីវុទ្ធី ក៏ពុំទាន់មានសិទ្ធជាម្ចាស់លើដីដែលជាកម្មវត្ថុនៃការប្តឹងចោទនេះនៅឡើយទេ ។

-យល់ឃើញថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខពន០០៦២១០ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដែលមានកំណត់ហេតុអង្កេតដី ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៣ ពុំបានយកចិត្តទុកដាក់ដល់ការបោះបង្គោលបេងហ៊ុំព័ទ្ធដីដែល អ៊ុន សំអឿន បានបោះហ៊ុំព័ទ្ធដីរបស់ខ្លួនដែរ ពិន ស៊ីវុទ្ធី ពុំទាន់បានឱ្យប្រាក់ថ្លៃដីគ្រប់នៅឡើយទេ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ហើយមេធាវីរបស់ឈ្មោះនេះ ក៏បានមកចូលរួមសវនាការនេះដែរ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទ័ណ្ឌលេខ២៦"គ" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះអ៊ុន សំអឿន**

**កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះមាស សាឯមជានី ប៉ុន្តែចាត់ទុកជាចំពោះមុខ ៈ**

១-ទទួលបណ្តឹងសាទុក្ខលេខ១០២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះអ៊ុន សំអឿន ទុកជាត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២៦ "គ" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ពេញទាំងមូល ដោយឥតបង្វិល ។

៣-សំរេចអោយឈ្មោះអ៊ុន សំអឿន រួចផុតពីបទចោទ ពីបទប៉ះពាល់កម្មសិទ្ធឯកជន ប្រព្រឹត្តនៅភូមិ១ សង្កាត់៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុកាលពីខែមិថុនា ឆ្នាំ២០០៣ តាមបញ្ញត្តិមាត្រា២៥៥ នៃច្បាប់ភូមិបាល ។

៤-សាលដីកានេះប្រកាសទោសវិនាការ ជាសាធារណៈ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៦ ។